អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ ល្បែងបង្កើតឧបករណ៍តន្ត្រីក្នុងរឿង រង់ភ្លេងក្មេងៗតាមភូមិ

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**សិក្សាសង្គម** ៖ ចម្រៀងនិងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី

៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយការបង្កើតរូបភាព

៖ គំនូរនិងសកម្មភាពកសាង៖

ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖ ប្រាប់បានពីរបៀបធ្វើចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងអ្វីមួយ។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។

បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

៖ វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទបត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន

បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖

ទី១. សម្ភារដែលត្រូវត្រៀមមានដូចជា៖ ទុយោរ ស្លឹកត្នោត ស្លឹកដូងឬក្រដាស។

ទី២. សម្ភារដែលត្រូវត្រៀមមានដូចជា៖ គម្របឆ្នាំង ឈើ ឬ ដុំថ្មជាដើម។

ទី៣. សម្ភារដែលត្រូវត្រៀមមានដូចជា៖  កន្ត្រៃ ទុយោរ កៅស៊ូ ប្រអប់ ក្រដាសឬសំបកទឹកដោះគោ ឬជាអ្វីក៏បានដែរ។

ទី៤. សម្ភារដែលត្រូវត្រៀមមានដូចជា៖ កាំបិត ចង្កឹះ កាវស្អិត ក្រណាត់ កៅស៊ូ ឬស្សី ឈើ ឧបករណ៍ចោះរន្ធ។

ទី៥. សម្ភារដែលត្រូវត្រៀមមានដូចជា៖ ធុងធំ ចង្កឹះ កំប៉ុងនំ ធុងថ្នាំពណ៌និងឈើ។

**ការរៀបចំ** ៖ បង្កើតឧបករណ៍តន្ត្រីដែលត្រៀមនឹងបង្កើតសម្រាប់បង្ហាញទៅកាន់កុមារ មុននឹងឱ្យកុមារចាប់ផ្ដើមលេង ឬបង្កើត នៅក្នុងថ្នាក់ទាំងអស់គ្នា។

**សេចក្ដីណែនាំ** ៖

1. ល្បែងនេះអាចលេងនៅក្រោយពេលដែលនិទានរឿង **វង់ភ្លេងក្មេងៗតាមភូមិ ក៏បានដែរ ស្រួលឱ្យកុមារបានដឹងច្បាស់ពីឧបករណ៍តន្ត្រីខ្លះៗនៅក្នុងសៀវភៅរឿងរបស់យើង។**
2. ដំបូងសួរកុមារពីឧបករណ៍តន្ត្រីជាមុនសិន ថាតើកុមារស្គាល់វាបានប៉ុន្មាន? ឱ្យកុមាររៀបរាប់ពីឧបករណ៍តន្ត្រីដែលពួកគេបានស្គាល់ ថាស្គាល់បានប៉ុណ្ណា?
3. ប្រាប់កុមារទាំងអស់ថា ថ្ងៃនេះពួកយើងនឹងបង្កើតឧបករណ៍តន្ត្រីចំនួនប្រាំប្រភេទ ដែលមាននៅក្នុងសាច់រឿងដែលកុមារបានស្ដាប់មុនហ្នឹង។
4. ចាប់ផ្ដើមប្រាប់កុមារពីរបៀបនៃការធ្វើឧបករណ៍នីមួយៗដែលបានរៀបរាប់ពីខាងលើ៖

**ទី១. របៀបបង្កើតប៉ីពកឬប៉ីអះ**

A. កាត់ទុយោរកន្លែងកាច់ចោល កាត់នៅចុងទុយោរជាស្រួច

B. ចុងក្រោយ គ្រាន់តែច្របាច់វាបន្តិចជាការស្រេច។

C. ការធ្វើប៉ីពកឬប៉ីអ មាន៤ប្រភេទក្នុងសកម្មភាពនេះ៖ ជាមួយទុយោរ ជាមួយស្លឹកត្នោត ទុយោរនិងក្រដាស និងជាមួយស្លឹកឈើក៏បានដែរ។

**ទី២. របៀបបង្កើតឈិង**

A. មានតែគម្របផ្ទាំងពីរចងខ្សែភ្ជាប់គ្នាជាការស្រេច។

B. ឈិងដែលធ្វើពីឈើនិងដុំថ្ម

**ទី៣. របៀបបង្កើតតាខេ**

A. ប្រអប់ក្រដាសជូតមាត់

B. ដាក់កៅស៊ូបីខ្សែនៅលើប្រអប់ក្រដាសជូតមាត់

C. ដាក់ចំកន្លែងដែលមានប្រហោង

D. កាត់ទុយោរសម្រាប់ធ្វើក្រចកដេញតាខេ

**ទី៤. របៀបបង្កើតរនាត**

A. ឈើវែងពីរ សម្រាប់ធ្វើជាស្នូក

B. ពុះបំពង់ឬស្សីជាពីរ ឱ្យបានមួយចំនួនធ្វើជាផ្លែរនាត

C. ដាក់ស្នូកពីរទន្ទឹមគ្នា

D. ដាក់បន្ទះឬស្សី(ផ្លែរនាត) គងលើស្នូក តម្រៀបគ្នាបែបនេះ ឱ្យបានស្អាត

E. ចាប់ផ្ដើមធ្វើអន្លូង

F. ដោយប្រើដុំឈើពីរដុំតូចៗនេះ

G. ចោះវាជាមួយឧបករណ៍ចោះរន្ធ(ប្រើអ្វីក៏បានដែរ)

H. ឈើចង្កឹះពីរ ដាក់ចូលក្នុងរន្ធដោយប្រើកាវស្អិត

I. ប្រើក្រណាត់រុំឈើអន្លូងជាការស្រេច។ រនាតនេះអាចធ្វើពីឬស្សីក៏បាន ពីកំណាត់ឈើក៏បានដែរ។

**ទី៥. របៀបបង្កើតស្គរ**

A. សម្រាប់ការធ្វើស្គរនេះ មិនពិបាកទេ គ្រាន់តែមានធុងនំ ធុងថ្នាំពណ៌ឬកំប៉ុងនំជាការស្រេច។

B. បន្ទាប់មក យកមកទះមកជាការស្រេច។